# ដឹងអំពីសិទ្ធិរបស់អ្នក

VOTE 2016

*ជាអ្នកបោះឆ្នោតនៅរដ្ឋ Minnesota អ្នកមានសិទ្ធិ ជាច្រើន–សូមស្វែងយល់អំពីសិទ្ធិទាំងនោះ!*

## ឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោតដោយគ្មានការកាត់ប្រាក់បៀវត្សរ៍ ការឈប់សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

## បោះឆ្នោតប្រសិនបើឈរតម្រង់ជួរនៅត្រឹម ម៉ោង 8 ល្ងាច

អ្នកមានសិទ្ធិបោះឆ្នោតប្រសិនបើអ្នកឈរតម្រង់ជួរ បោះឆ្នោតនៅក្នុងពេលណាមួយមុនម៉ោង8យប់។

## ចុះឈ្មោះនៅថ្ងៃបោះឆ្នោត

អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត ប្រសិនបើអ្នកអាចបង្ហាញភ័ស្តុតាងអំពីទីកន្លែងរស់នៅរបស់អ្នក។

## ចុះឈ្មោះដោយផ្ទាល់មាត់

អ្នកមានសិទ្ធិបញ្ជាក់ដោយផ្ទាល់មាត់អំពីអត្តសញ្ញាណរបស់អ្នក និងស្នើឱ្យបុគ្គលផ្សេងទៀតចុះហត្ថខាផ្សេងទៀតចុះហត្ថលេខាជំនួសអ្នក ប្រសិនបើអ្នកមិនអាចចុះហត្ថលេខាឈ្មោះរបស់អ្នក។

## ស្នើសុំជំនួយ

អ្នកមានសិទ្ធិស្នើសុំជំនួយពីអ្នកដទៃ លើកលែងតែ ភ្នាក់ងារនៃនិយោជក ឬសហជីពរបស់អ្នក ឬបេក្ខជន បោះឆ្នោត។

## យកកូនទៅស្ថានីយបោះឆ្នោត

អ្នកមានសិទ្ធិនាំកូនរបស់អ្នកទៅបោះឆ្នោត។

### កាលបរិច្ឆេទឆ្នាំ 2016

**ការបោះឆ្នោតបឋម**
*ថ្ងៃអង្គារ៍ទី09 ខែសីហា*

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
*បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា*

**ចុះឈ្មោះបោះឆ្នោត**
*ចុះឈ្មោះជាមុននៅត្រឹមថ្ងៃទី18 ខែតុលា ដើម្បីសន្សំសំចៃពេលវេលានៅថ្ងៃបោះឆ្នោត។*

**ថ្ងៃបោះឆ្នោត**
*ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា*

*តទៅទំព័រក្រោយ...*

*ការិយាល័យលេខាធិការរដ្ឋ Minnesota*
*mnvotes.org • 1-877-600-VOTE*

# ដឹងអំពីសិទ្ធិរបស់អ្នក

VOTE 2016

.... តពីទំព័រមុខ

## បោះឆ្នោតបន្ទាប់ពីត្រូវបានកាត់ទោសបទឧក្រិដ្ឋ

អ្នកអាចបោះឆ្នោតនៅក្រោយពីអ្នកបញ្ចប់គ្រប់ផ្នែក ទាំងអស់នៃការកាត់ទោសរបស់អ្នក រួមទាំងរយៈពេល សាកល្បង ការដោះលែងមុនកំណត់ ឬលក្ខខណ្ឌ ផ្សេងៗទៀតដូចជា ការស្តារឡើងវិញជាដើម។

## បោះឆ្នោតប្រសិនបើស្ថិតនៅក្រោមការឃ្លាំមើល

អ្នកអាចបោះឆ្នោតនៅពេលស្ថិតក្រោមការឃ្លាំមើលបានលុះត្រាតែចៅក្រោមមិនបាន លុបចោលសិទ្ធិបោះឆ្នោតរបស់អ្នក។

## បោះឆ្នោតដោយមិនរង ឥទ្ធិពលពីនរណាម្នាក់

អ្នកមានសិទ្ធិបោះឆ្នោតដោយពុំមាននរណាម្នាក់នៅ កន្លែងបោះឆ្នោតព្យាយាមប្រើ ឥទ្ធិពលមកលើការ បោះឆ្នោតរបស់អ្នក។

## ប្តូរសន្លឹកឆ្នោតថ្មី

អ្នកមានសិទ្ធិប្តូរសន្លឹកឆ្នោតថ្មីប្រសិនបើអ្នកគូសសន្លឹក ឆ្នោតដោយច្រឡំមុនពេលអ្នក ដាក់សន្លឹកឆ្នោតទៅក្នុង ហឹបឆ្នោត។

## ដាក់ពាក្យប្តឹង

អ្នកមានសិទ្ធិដាក់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅ ទីកន្លែងបោះឆ្នោតរបស់អ្នក ប្រសិនបើអ្នកមិនពេញចិត្ត ចំពោះការរៀបចំដំណើរការបោះឆ្នោត។

## ដាក់សន្លឹកឆ្នោតគំរូតាមខ្លួន

អ្នកមានសិទ្ធិយកសន្លឹកឆ្នោតគំរូចូលក្នុងកន្លែងគូស សន្លឹកឆ្នោត។

## ដាក់ឯកសារសិទ្ធិអ្នកបោះឆ្នោតតាមខ្លួន

អ្នកមានសិទ្ធិយកឯកសារសិទ្ធិអ្នកបោះឆ្នោតចូលក្នុង កន្លែងគូសសន្លឹកឆ្នោត។

**ការិយាល័យលេខាធិការរដ្ឋ Minnesota**
**mnvotes.org • 1-877-600-VOTE**

ខែមីនា ឆ្នាំ2016